**មាត្រា ២** : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានពេញ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ប្រធានរដ្ឋសភា**

**ជា ស៊ីម**

* * *

## ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៥

## យើងព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលជាតិកម្ពុជា
- តាមសេចក្តីស្នើរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ :

**ទ្រង់ត្រាសសំរេច :**

**មាត្រា ១** : បង្កើតអាជ្ញាធរជាតិមួយសំរាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែនហៅថា «អាជ្ញាធរ ជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលមានសមាសភាពដូចតទៅ :

១–សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១

២–សម្តេច នាយករដ្ឋមន្ត្រីទី២ សហប្រធាន
៣–សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន
៤–រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
៥–ឯកឧត្តម **ឌិត មុន្ទី** អតីតប្រធានគណៈកម្មាធិការព្រំដែន ទីប្រឹក្សាប្រចាំអាជ្ញាធរ
៦–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៧–រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៨–សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក
៩–អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
១០–ឯកឧត្តម **វ៉ា គីមហុង** ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយក រដ្ឋមន្ត្រីទី២ ទទួលបន្ទុកការងារព្រំដែនឋានៈស្មើរដ្ឋលេខាធិការ សមាជិកអចិន្ត្រៃយ៍
១១–ឯកឧត្តម **ឡុង ទិសារលោ** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ សមាជិក
១២–ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការ

**មាត្រា ២** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច ÷

– រៀបចំ និងកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ស្តីពីការកំណត់ព្រំដែនដីគោក និង ព្រំដែនសមុទ្រ ដើម្បីយកទៅតំកល់នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

–ស្រាវជ្រាវនិងសិក្សាអោយបានហ្មត់ចត់បំផុត ក្នុងការជ្រើសរើសយកផែនទីលំនាំណាមួយសំរាប់ធ្វើការកំណត់បន្ទាត់ព្រំដែនដីគោកនិងព្រំដែនសមុទ្រអោយបានច្បាស់លាស់ រវាងព្រះ រាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង ។

–ធ្វើការចរចា សំរបសំរួល ដោះស្រាយ និងសំរេចលើបញ្ហាព្រំដែនជាមួយបណ្តាប្រទេសជិតខាងលើរាល់កិច្ចការដែលមានទំនាក់ទំនងលើការងារព្រំដែន ក្រោយពីមានការឯកភាពពីគណៈរដ្ឋមន្ត្រី ។

–សហប្រធានមានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបញ្ហាព្រំដែន ក្នុងនាមអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ៣** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានយន្តការ ២ ជាលេខាធិការ :

**យន្តការទី១** :ជាគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែន(Task Force sur létude juridique)សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**យន្តការទី២**:ជាគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ( Task Force Technique) ។ សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤** : យន្តការទាំងពីរនេះមានលេខាធិការដ្ឋានរួមមួយអចិន្ត្រៃយ៍ នៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ហៅថា : លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនដែលមាន ÷

- ឯកឧត្តម **វ៉ា គឹមហុង** ជាសមាជិកអចិន្ត្រៃយ៍អាជ្ញាធរទទួលបន្ទុកលេខាធិការដ្ឋាន
- ឯកឧត្តម **ម្រាស់ លោស់** ជាជំនួយការទទួលបន្ទុកលេខាធិការដ្ឋាន
- ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការអាជ្ញាធរ ជាប្រធានលេខាធិការដ្ឋាន
- ប្រធាននាយកដ្ឋានសូរិយោដី អនុប្រធានលេខាធិការដ្ឋាន
- លេខាធិការនៃគណៈកម្មាធិការនីតិកម្ម ស្តីពីកិច្ចការព្រំដែន ជាសមាជិក
- លេខាធិការនៃគណៈកម្មាធិការបច្ចេកទេស ស្តីពីកិច្ចការព្រំដែន ជាសមាជិក
- មន្ត្រីជំនាញការមួយចំនួន តាមសេចក្តីត្រូវការជាក់ស្តែង

លេខាធិការដ្ឋាននេះ ជាអ្នកសំរបសំរួលកិច្ចការ រវាងគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែន និងគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ហើយជាក្បាលម៉ាស៊ីនរដ្ឋបាល និងជាហិរញ្ញកិច្ចរបស់អាជ្ញាធរ ជាតិទទួលបន្ទុកកិច្ចការព្រំដែន ដោយប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានភូមិសាស្ត្រ នាយកដ្ឋានសូរិយោដី មន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ និងមន្ត្រីនៃលេខាធិការដ្ឋានរបស់យន្តការទាំង២ សំរាប់ជំនួយការ ។ លេខាធិការដ្ឋាន អចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទទួលបន្ទុកកសាងផែនការ ចំណាយរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា ៥** : លេខាធិការដ្ឋាន មានភារកិច្ច ÷

-សិក្សាស្រាវជ្រាវនិងស្វែងយល់បន្ថែមលើការងារបច្ចេកទេស ដែលពាក់ព័ន្ធទៅ នឹងបញ្ហាព្រំដែនដើម្បីរៀបចំ និង កសាងដោយផ្ទាល់អោយបានលិខិតបទដ្ឋានមានលក្ខណៈច្បាប់ សំរាប់យកទៅដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ចុះពិនិត្យនិងធ្វើការវាស់វែងដល់ទីកន្លែងកើតហេតុនានាតាមបណ្តោយព្រំដែន រួចរាយការណ៍ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និង សំរេច ។

-ចូលរួមចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ជ្រើសរើសយកផែនទីសំរាប់ធ្វើជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបច្ចេកទេសអោយបានត្រឹមត្រូវច្បាស់លាស់ ។

-សហការជាមួយអភិបាល ឬ អភិបាលរងខេត្ត ក្រុងដែលនៅជាប់ព្រំដែនជាមួយប្រទេសជិតខាងក្នុងការសិក្សាស្រាវជ្រាវលើទីតាំងព្រំដែន សីមា ជាក់ស្តែងទៅនឹងបញ្ហាបច្ចេកទេសជំនាញ រួចរាយការណ៍អំពីលទ្ធផល ជូនអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ព្រំដែនជាមួយប្រទេសជិតខាង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់រាយការណ៍ ថ្វាយនិងជូនគណៈរដ្ឋមន្ត្រី ។

**មាត្រា ៦** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី សំរាប់សំរួលការងារ ។

សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា ៧** : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនមានខ្ទង់ថវិកាដោយឡែក សំរាប់ចំណាយដោយផ្ទាល់ក្នុងការងាររបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៨** : សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា រដ្ឋមន្ត្រីពាក់ព័ន្ធ រដ្ឋមន្ត្រីនិងអគ្គភាពសាមី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជ ក្រឹត្យនេះ ។

**មាត្រា ៩** : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះរាជហស្ថលេខានេះតទៅ

ហើយ ជំនួសអោយព្រះរាជក្រឹត្យលេខ នសរកត ០២៩៥-១៩ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ដែលត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *